**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០១៥/២១ **ក.ប**/ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រើប្រាស់ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត និងការធ្វើការងារនៅក្នុងអំឡុងពេលការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

យោងសេចក្តីសម្រេចលេខ៤៤សសរ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២១ ស្តីពីការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសជាបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស, កម្មករនិយោជិត និងបុគ្គលិក, និងអ្នកបើកបរ ឬម្ចាស់មធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិក ដូចខាងក្រោម៖

**ក-ចំពោះកម្មករនិយោជិត និងបុគ្គលិក**

- អ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន និងធ្វើដំណើរតែម្នាក់ឯងត្រូវយកតាមខ្លួននូវ (១) កាតសម្គាល់កម្មករនិយោជិត ឬបុគ្គលិក, និង (២) អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារដែលអាចបញ្ជាក់ពីទីលំនៅបច្ចុប្បន្នរបស់ខ្លួន នៅរៀងរាល់ពេលធ្វើដំណើរទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះ ដើម្បីបង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ច។
- អ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើររួមត្រូវ (១) ជិះមធ្យោបាយដែលមាន "ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត" ចេញដោយក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង (២) យកតាមខ្លួននូវកាតសម្គាល់កម្មករនិយោជិត និងបុគ្គលិក នៅរៀងរាល់ពេលធ្វើដំណើរទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះ ដើម្បីបង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ច។

**ខ-ចំពោះម្ចាស់ ឬនាយករោងចក្រ សហគ្រាស**

- ត្រូវផ្តល់បញ្ជីស្លាកលេខរថយន្ត ឬមធ្យោបាយដឹកជញ្ជូនដល់អធិការការងារ។
- ត្រូវសហការជាមួយអធិការការងារ ដើម្បីផ្តល់ "ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត" ដល់អ្នកបើកបរ (ដូចមានគំរូជូនភ្ជាប់ជាមួយ) សម្រាប់បង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ចនៅពេលដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិកទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- ត្រូវធានាថាកម្មករនិយោជិត និងបុគ្គលិកទាំងអស់មានកាតសម្គាល់ខ្លួន។ ក្នុងករណីបាត់ ត្រូវចេញកាតសម្គាល់ខ្លួនជូនកម្មករនិយោជិត និងបុគ្គលិកជាបន្ទាន់។

**គ-ចំពោះអ្នកបើកបរ ឬម្ចាស់មធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិក**

- ត្រូវមកទទួលយក "ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត" ពីរោងចក្រ សហគ្រាស និងត្រូវដាក់បង្ហាញនៅផ្នែកខាងមុខមធ្យោបាយដឹកជញ្ជូន ដើម្បីបង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ច។

ក្រសួងមានសេចក្តីជឿជាក់ថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស, កម្មករនិយោជិត និងបុគ្គលិក, និងអ្នកបើកបរ ឬម្ចាស់មធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិកទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ អង្គារ ៩ រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**:
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ក្រសួង ស្ថាប័នពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- -មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- -អង្គការវិជ្ជាជីវៈគ្រប់លំដាប់ថ្នាក់

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- -ឯកសារ កាលប្បវត្តិ

# ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ:..................................

ស្លាកលេខរថយន្ត:................................

ទំនាក់ទំនងទូរស័ព្ទលេខ:

០១២ ៣០០ ១១៨

០១២ ៩៦៦ ៤១៦

០៩២ ៤២៤ ០៥០

**សុពលភាពចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១**

**សម្រាប់ចម្ងាយផ្លូវពី.........................ទៅ...........................**

# ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត

## មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត...............................

លេខ:.................................

ស្លាកលេខរថយន្ត:...............................

ទំនាក់ទំនងទូរស័ព្ទលេខ:

០១២ ### ###

០១២ ### ###

**សុពលភាពចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១**

**សម្រាប់ចម្ងាយផ្លូវពី.........................ទៅ.........................**